# របាយការណ៍កិច្ចប្រជុំ
# ពិនិត្យមើលលទ្ធផលការងារ៦ខែដើមឆ្នាំ២០១៧របស់ក្រុម ការងារថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រយុទ្ធនឹងជំងឺអេដស៍



**ថ្ងៃទី០៦-០៧ ខែកញ្ញា ឆ្នាំ២០១៧**

**ខេត្តបន្ទាយមានជ័យ**

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧ ឯកឧត្តមអគ្គលេខាធិការបានចូលរួមដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំ ដើម្បីពិនិត្យមើលលទ្ធផលការងារ៦ខែដើមឆ្នាំ២០១៧ របស់ក្រុមការងារថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដែលគាំទ្រដោយអង្គការសេវាសង្គមសុខភាពបុរស (MHSS)។

**១- ការជួបពិភាក្សាជាមួយគណៈកម្មាធិការ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត**

វេលាម៉ោង០២:៣០នាទីរសៀល ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ **ឯកឧត្តមវេជ្ជអគ្គលេខាធិការ** បានដឹកនាំក្រុមការងារជួបជាមួយអភិបាលនៃគណៈអភិបាល និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តទៅតាមកម្មវិធីដែលបានគ្រោងទុក។

កិច្ចប្រជុំ បានដំណើរការទៅ ដោយមានការចូលរួមពីលោកជំទាវតំណាងឯកឧត្តមអភិបាលនៃគណៈអភិបាល និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត លោកប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត មន្ត្រីកម្មវិធីអេដស៍ខេត្ត អាជ្ញាធរដែនដី អង្គការ MHSS អង្គការ KHANA និងមន្ទីរពាក់ព័ន្ធមួយចំនួននៅជុំវិញខេត្តប្រមាណ៣០នាក់។



ជាកិច្ចចាប់ផ្ដើមជំនួសមុខឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមអគ្គលេខាធិការ បានកោតសរសើរកិច្ចខិតខំប្រឹងប្រែងកន្លងមករបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត និងសមាជិកដែលបានអនុវត្តការងារអេដស៍ប្រកបដោយលទ្ធផលល្អ។ ក្នុងជំនួបនោះឯកឧត្តមអគ្គលេខាធិការ បានជម្រាបជូនបញ្ហាមួយចំនួនដែលយើងកំពុងបន្តអនុវត្ត និងបញ្ហាប្រឈមដែលកើតមានឡើងនៅក្នុងខេត្ត មានជាអាទិ៍ ៖

- ត្រូវបន្តផ្សព្វផ្សាយគោលនយោបាយប្រើប្រាស់ស្រោមអានាម័យ១០០%។
- ត្រូវអនុវត្តនូវគោលនយោបាយ៧ចំណុចរបស់រាជរដ្ឋាភិបាល ដើម្បីជំរុញការប្រើប្រាស់ស្រោមអានាម័យ១០០%។

- ត្រូវអនុវត្តសេចក្តីសម្រេចនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៧ ដើម្បីអនុវត្តនូវការដាក់បញ្ចូលកម្មវិធីអេដស៍ទៅក្នុងកម្មវិធីភូមិ-ឃុំមានសុវត្ថិភាព។
- អង្គការ AHF បានឯកភាពជាមួយលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត លើការរៀបចំមណ្ឌល សំចត ដើម្បីស្វែងរកការចម្លងអេដស៍ថ្មី។
- អង្គការ AHF ក៏បានសហការជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរៈភូមិន្ទ លើការងារអប់រំ ផ្សព្វផ្សាយមេរោគអេដស៍ និងជំងឺអេដស៍ និងការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត ដល់កងយោធពលខេមរៈភូមិន្ទនៅតាមបណ្តាអង្គភាពចំណុះនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរៈភូមិន្ទ ជាពិសេសនៅតាមបណ្តាព្រំដែនដែលមានទំនាក់ទំនងជាមួយខេត្ត ដែលចាំបាច់ត្រូវមានការសហការ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្រសួងផែនការ បានផ្តល់ប័ណ្ណក្រីក្រជូនអ្នកផ្ទុកមេរោគអេដស៍ដែលក្រីក្រ ដើម្បីទទួលសេវាថែទាំសុខភាព។
- ស្នើឱ្យអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរមានសមត្ថកិច្ច ជួយសហការ និងសម្របសម្រួលឱ្យម្ចាស់គ្រឹះស្ថានសេវាកម្សាន្តសប្បាយ ម្ចាស់កាស៊ីណូ សហការឱ្យក្រុមការងារចុះអប់រំផ្សព្វផ្សាយអេដស៍ដល់ស្ត្រីបម្រើសេវាកម្សាន្តសប្បាយនៅតាមកន្លែងសេវាកម្សាន្តសប្បាយ និងតាមកាស៊ីណូនៅក្នុងក្រុងប៉ោយប៉ែត ដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍។

ឯកឧត្តមអគ្គលេខាធិការបានបញ្ជាក់ និងសង្កត់ធ្ងន់ផងដែរលើកិច្ចខិតខំប្រឹងប្រែងកន្លងមក ជាពិសេសការដាក់បញ្ចូលបញ្ហាអេដស៍ចូលក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។

ក្រោយពីបានស្តាប់ការងារដែលត្រូវអនុវត្តបន្ត និងបញ្ហាប្រឈម ដែលកើតឡើងនៅក្នុងខេត្តរួចមក លោកជំទាវតំណាងអភិបាលនៃគណៈអភិបាល និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ក៏បានឯកភាព និងរួមសហការដើម្បីដោះស្រាយ ដោយលោកជំទាវលើកឡើងដូចខាងក្រោម៖

- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងលេខាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត នឹងសហការ និងជួយសម្របសម្រួលរាល់កិច្ចការទាំងអស់ដែលកើតមានឡើង។
- ស្នើឱ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងខេត្តទាំងមូល មានឆន្ទៈសហការ និងចូលរួមទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍។
- អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ និងមន្ទីរអង្គភាពដែលពាក់ព័ន្ធ ត្រូវសហការ និងជួយសម្របសម្រួលរាល់បញ្ហាដែលកើតឡើង។
- អង្គការសង្គមស៊ីវិល បើមានការលំបាកក្នុងការអនុវត្តការងារ ត្រូវទាក់ទងមកគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ឬក៏លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ដើម្បីជួយសម្របសម្រួល និងដោះស្រាយ។

ជាចុងបញ្ចប់ឯកឧត្តមអគ្គលេខាធិការ បានជូនឯកសារទៅគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត រួមមាន៖

- គោលនយោបាយ៧ចំណុច ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣។
- ផែនការណែនាំ ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦។

- គោលការណ៍ការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៩។
- សេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៧ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧។

**២-ការចុះពិនិត្យ និងស្វែងយល់ស្ថានភាពអេដស៍នៅតាមគ្រឹះស្ថានសេវាកម្សាន្ត និងតាមកាស៊ីណូ ក្រុងប៉ោយប៉ែត**

វេលាម៉ោង០៤:៤៥នាទីរសៀល ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំក្រុមការងារចុះពិនិត្យ និងស្វែងយល់ពីស្ថានភាពអេដស៍នៅតាមកន្លែងសេវាកម្សាន្តសប្បាយ និងតាមកាស៊ីណូនៅក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ក្នុងនោះដោយបានទទួលនូវបញ្ហាប្រឈមចំនួន ដូចខាងក្រោម៖

- ករណីស្ត្រីរកឃើញប្រតិកម្មតេស្ត ហើយមិនព្រមទៅធ្វើតេស្តបញ្ជាក់(ក្រុងប៉ោយប៉ែត) ដោយខ្លាចម្ចាស់ហាងដឹង និងមានការរើសអើង ហើយមិនព្រមឱ្យក្រុមការងារជួបធ្វើការអប់រំ។
- តាមគ្រឹះស្ថានសេវាកម្សាន្តសប្បាយ និងកាស៊ីណូខ្លះ មិនព្រមឱ្យក្រុមការងារចុះជួបស្ត្រីបម្រើសេវាកម្សាន្តសប្បាយធ្វើតេស្តឈាមរកមេរោគអេដស៍(ក្រុងប៉ោយប៉ែត)។
- ស្ត្រីផ្ទុកមេរោគអេដស៍ខ្លះបាត់មុខខ្លាចប៉ូលីសចាប់ ដោយពួកគាត់ប្រើប្រាស់គ្រឿងញៀន (ស្ត្រីខារ៉ាអូខេនៅសេរីសោភ័ណ្ឌ១០នាក់ និងក្រុងប៉ោយប៉ែត១០នាក់)។

**៣-កិច្ចប្រជុំពិនិត្យមើលលទ្ធផលការងារ៦ខែដើមឆ្នាំ២០១៧របស់ក្រុមការងារថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧។**

ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោង០៨:៣០នាទីព្រឹក **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំ ដើម្បីពិនិត្យមើលលទ្ធផលការងារ៦ខែដើមឆ្នាំ២០១៧ របស់ក្រុមការងារថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដែលគាំទ្រដោយអង្គការសេវាសង្គមសុខភាពបុរស (MHSS)។

កិច្ចប្រជុំ បានដំណើរការទៅ ដោយមានការចូលរួមពីប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត មន្ត្រីកម្មវិធីអេដស៍ខេត្ត មន្ទីរពាក់ព័ន្ធនៅជុំវិញខេត្ត អាជ្ញាធរដែនដីមានអភិបាលក្រុង មេបញ្ជាការកងរាជអាវុធហត្ថក្រុង អធិការនគរបាលក្រុង នាយនគរបាលប៉ុស្តិ៍សង្កាត់ អង្គការសង្គមស៊ីវិលមានអង្គការ MHSS អង្គការ KHANA អង្គការអភិវឌ្ឍន៍គ្រួសារក្រីក្រ ក្រុមគោលដៅចំនួនសរុប៩៩នាក់ ក្នុងនោះស្រីចំនួន២១នាក់។

កិច្ចប្រជុំពិភាក្សាដោយផ្តោតទៅលើបញ្ហាប្រឈមដែលកើតមានឡើង ដូចខាងក្រោម ៖

- ស្នើសុំឱ្យអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ និងមន្ទីរអង្គភាពដែលពាក់ព័ន្ធជួយសហការ និងជួយសម្របសម្រួលរាល់បញ្ហាដែលកើតមានឡើង។
- អង្គការសង្គមស៊ីវិល និងក្រុមគោលដៅ មានការលំបាកក្នុងការចុះធ្វើតេស្តឈាមរកមេរោគអេដស៍ និងទៅទទួលសេវាព្យាបាលជំងឺកាមរោគ។

- ករណីស្ត្រីរកឃើញប្រតិកម្មតេស្ត ហើយមិនព្រមទៅធ្វើតេស្តបញ្ជាក់(ក្រុងប៉ោយប៉ែត) ដោយខ្លាចម្ចាស់ហាងដឹង និងមានការរើសអើង ហើយមិនព្រមឱ្យក្រុមការងារជួបធ្វើការអប់រំ។
- តាមគ្រឹះស្ថានសេវាកម្សាន្តសប្បាយ និងកាស៊ីណូខ្លះ មិនព្រមឱក្រុមការងារចុះជួបស្ត្រីបម្រើសេវាកម្សាន្តសប្បាយធ្វើតេស្តឈាមរកមេរោគអេដស៍(ក្រុងប៉ោយប៉ែត)។
- ស្ត្រីផ្ទុកមេរោគអេដស៍ខ្លះលាក់មុខខ្លាចប៉ូលីសចាប់ ព្រោះពួកគាត់ប្រើប្រាស់គ្រឿងញៀន (ស្ត្រីខារ៉ាអូខេនៅសេរីសោភ័ណ្ឌ១០នាក់ និងក្រុងប៉ោយប៉ែត១០នាក់)។
- ការថយចុះនៃថវិកាគម្រោង ធ្វើឱ្យប៉ះពាល់ដល់ការបញ្ជូនទៅរកសេវាសុខភាព និងអាចប្រឈមនឹងការបោះបង់ថ្នាំ។
- ពិបាកក្នុងការស្វែងរកក្រុមគោលដៅថ្មី។



ក្រោយពីការពិភាក្សារួចមក ឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានអង្គប្រជុំក៏បានផ្តល់ការណែនាំបន្ថែមដូចតទៅ ៖

១.ស្នើសុំឱ្យអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ និងមន្ទីរអង្គភាពដែលពាក់ព័ន្ធ ជួយសហការ និងជួយសម្របសម្រួលរាល់បញ្ហាដែលកើតមានឡើង។
២.ស្នើសុំឱ្យអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់(ក្រុងប៉ោយប៉ែត) ជួយសម្របសម្រួលឱ្យក្រុមការងារ បានចុះទៅតាមគ្រឹះស្ថានសេវាកម្សាន្តសប្បាយ និងកាស៊ីណូ ដែលមិនព្រមឱក្រុមការងារចុះជួបស្ត្រីបម្រើសេវាកម្សាន្តសប្បាយធ្វើតេស្តឈាមរកមេរោគអេដស៍។
៣.ករណីស្ត្រីរកឃើញប្រតិកម្មតេស្ត ហើយមិនព្រមទៅធ្វើតេស្តបញ្ជាក់(ក្រុងប៉ោយប៉ែត) ក្រុមការងារត្រូវព្យាយាមជួបគាត់ ដើម្បីធ្វើអប់រំឱ្យគាត់យល់ពីការថែទាំសុខភាពរបស់គាត់។
៤.សុំឲ្យមានការបង្កើនសមត្ថភាព ក្នុងការរៀបពន្យល់ ដើម្បីយល់ទាំងអស់គ្នាជាពិសេសដំណោះស្រាយក្រុមប្រឈមមុខខ្ពស់។

៥.ការងារប្រយុទ្ធនឹងជំងឺអេដស៍ មិនចេះតែធ្វើនោះទេ គឺមានគោលការណ៍ និងផែនការច្បាស់លាស់ជាមូលដ្ឋានក្នុងការអនុវត្ត ជាក់ស្តែង ដូចជាមានគោលការណ៍៧ចំណុចរបស់រាជរដ្ឋាភិបាល គោលការណ៍ប្រើប្រាស់ស្រោមអនាម័យ១០០% និងសេចក្តីសម្រេចនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៧របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដូច្នេះ ជាទិសដៅរបស់រដ្ឋាភិបាលដែលយើងត្រូវអនុវត្ត ដើម្បីគោលនយោបាយជាតិទាំងអស់គ្នា។

៦.អង្គការសង្គមស៊ីវិល បើមានការលំបាកក្នុងការអនុវត្តការងារ ត្រូវទាក់ទងមកគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ឬក៏លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ដើម្បីជួយសម្របសម្រួល និងដោះស្រាយ។

៧.អង្គការសង្គមស៊ីវិល និងក្រុមការងារដែលធ្វើការងារអេដស៍ ត្រូវចូលរួមប្រជុំជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ឬក៏លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តប្រចាំខែ។

៨.ក្រុមការងារចុះធ្វើការងារនៅតាមមូលដ្ឋាន ត្រូវរៀបចំបញ្ជីឈ្មោះអ្នកចុះធ្វើការងារដោយមានរូបថតផ្ញើទៅអាជ្ញាធរមានសមត្ថកិច្ចបានស្គាល់ ហើយពេលចុះធ្វើការងារ ត្រូវជូនដំណឹងទៅសមត្ថកិច្ច និងមានពាក់ស្លាកឈ្មោះក្នុងពេលចុះធ្វើការងារ។

**ចំណុចខ្លាំង**

- មានការគាំទ្រពីគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត។
- មានការយកចិត្តទុកដាក់ដឹកនាំដោយផ្ទាល់ពីថ្នាក់ដឹកនាំខេត្ត រួមទាំងស្ថាប័នពាក់ព័ន្ធ ។

**ចំណុចដែលនៅខ្វះខាត**

- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត និងអង្គការពាក់ព័ន្ធមួយចំនួនបន្តអនុវត្ត និងតាមដានបញ្ហាដែលកើតមាន នៅក្នុងកិច្ចប្រជុំលើកក្រោយទៀត។

ធ្វើនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧

**អគ្គលេខាធិការ**

**ឯកឧត្តមវេជ្ជ តៃង ឥន្ទី**

3-10-17